**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៣៧ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី៣១ខែមីនា ឆ្នាំ២០១៦

# ប្រកាស
## ស្តីពី
## បែបបទ និងនីតិវិធីចំណាយលើការងារអន្តរាគមន៍ជួសជុលបន្ទាន់ផ្លូវជនបទ ស្ពាន និងលូ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់ការងារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

## សម្រេច

**ប្រការ១:** ត្រូវបានបម្រុងឥណទានថវិកាមិនលើសពីចំនួន ២០% (ម្ភៃភាគរយ) នៃឥណទានថវិកាជំពូក៦១ (ការងារជួសជុលនិងថែទាំផ្លូវជនបទ) នៃកញ្ចប់ថវិកាក្រសួងអភិវឌ្ឍន៍ជនបទប្រចាំឆ្នាំ សម្រាប់ត្រៀមប្រើប្រាស់អន្តរាគមន៍ជួសជុលបន្ទាន់ផ្លូវជនបទ ស្ពាន និងលូទាំងឡាយណាដែលកំពុងដំណើរការ ហើយត្រូវបានខូចខាត/កាត់ផ្តាច់ ឬ រកកល់នឹងខូចខាត/កាត់ផ្តាច់ ដោយប្រការណាមួយ។

**ប្រការ២:** ថវិកានេះនឹងត្រូវផ្តល់ជូនអង្គភាពជំនាញក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ តាមរបៀបដូចខាងក្រោម÷

- នៅរៀងរាល់ដើមឆ្នាំ ក្រោយពីទទួលបានសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ថវិកាចំនួន ៥០% (ហាសិបភាគរយ) នៃកញ្ចប់ថវិកាអន្តរាគមន៍ជួសជុលបន្ទាន់ នឹងត្រូវផ្តល់ជូនមុនតាមរយៈបុរេប្រទាន។
- ការបើកផ្តល់បន្ទាប់មកទៀត នឹងត្រូវធ្វើឡើងក្រោមរូបភាពជាការបំពេញឡើងវិញនូវថវិកាដែលបានចំណាយ រហូតដល់អស់កញ្ចប់ឥណទានថវិកាបម្រុងប្រចាំឆ្នាំ។
- ដើម្បីសម្រួលដល់ការបំពេញថវិកាឡើងវិញឱ្យមានប្រសិទ្ធិភាពខ្ពស់ របាយការណ៍ចំណាយ និងរបាយការណ៍អនុវត្តការងារ ត្រូវផ្តល់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុភ្លាម ក្រោយពេលមុខចំណាយនីមួយៗត្រូវបានអនុវត្តចប់សព្វគ្រប់។ ក្នុងករណីមានភាពមិនច្បាស់លាស់ណាមួយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចស្នើឱ្យមានការបំភ្លឺបន្ថែម ឬចុះពិនិត្យដល់ការដ្ឋាន មុននឹងផ្តល់ថវិកាបំពេញឡើងវិញ។

**ប្រការ៣:** អង្គភាពជំនាញក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ សំដៅដល់ នាយកដ្ឋានជំនាញ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ជាអ្នកទទួលបន្ទុកអនុវត្តការងារអន្តរាគមន៍ជួសជុលបន្ទាន់នេះ។ ហាមដាច់ខាតប្រគល់សិទ្ធិឱ្យក្រុមហ៊ុនឯកជនម៉ៅការអនុវត្តបន្ត លើកលែងតែក្នុងករណីមានការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន។

**ប្រការ៤:** ទឹកប្រាក់អតិបរមាចំនួន ២០០ (ពីររយ) លានរៀល នឹងត្រូវអនុញ្ញាតឱ្យចំណាយសម្រាប់មុខសញ្ញាអន្តរាគមន៍ជួសជុលបន្ទាន់នីមួយៗ។ ក្នុងករណីដែលមានតម្រូវការចំណាយថវិកាច្រើនជាងនេះ ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ៥:** ក្នុងករណីដែលពិនិត្យឃើញថារហូតដល់ដំណាច់ឆ្នាំ ថវិកាមិនអាចចំណាយអស់ ឥណទានថវិកាដែលនៅសល់អាចបង្វែរទៅប្រើប្រាស់សម្រាប់ការងារជួសជុល និងថែទាំផ្លូវជនបទផ្សេងទៀតដែលកំពុងមានតម្រូវការចាំបាច់ បន្ទាប់ពីមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៦:** សាច់ប្រាក់ដែលបានបើកផ្តល់ជាបន្តបន្ទាប់ក្នុងឆ្នាំ ហើយនៅសល់មិនបានចំណាយ ត្រូវបង់ចូលថវិកាជាតិវិញនាដំណាច់ឆ្នាំ តាមរូបភាពជាសំណោះចំណាយ។

**ប្រការ៧:** ថវិកាចំនួន ៥០% (ហាសិបភាគរយ) ដូចចែងក្នុង **ប្រការ២** សម្រាប់ឆ្នាំបន្ទាប់ នឹងត្រូវផ្តល់ជូន ក្រោយពីរបាយការណ៍ទូទាត់ចំណាយក្នុងឆ្នាំកន្លងទៅទាំងអស់ និងរបាយការណ៍ស្តីពីការបង់សំណោះចំណាយ ត្រូវបានផ្តល់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៨ :** កម្មវត្ថុចំណាយដូចមានចែងក្នុង **ប្រការ១** ខាងលើ មិនគ្របដណ្តប់លើការខូចខាតទាំងឡាយណាដែលបណ្តាលមកពីបទល្មើសនៃការដឹកជញ្ជូនលើសទម្ងន់កំណត់ទេ ដោយការងារនេះស្ថិតក្រោមការទទួលខុសត្រូវផ្ទាល់របស់សមត្ថកិច្ចពាក់ព័ន្ធនានា ក្នុងការទប់ស្កាត់ និងចាប់ឲ្យជនប្រព្រឹត្តបទល្មើសទទួលខុសត្រូវចំពោះមុខច្បាប់ និងសងនូវការខូចខាត។

**ប្រការ៩:** ហាមដាច់ខាត ចំពោះការប្រើប្រាស់កញ្ចប់ថវិកាអន្តរាគមន៍ជួសជុលបន្ទាន់ខុសពីគោលដៅដូចមានចែងក្នុង **ប្រការ១** ខាងលើ រាប់ទាំងការចំណាយលើប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រាក់ឧបត្ថម្ភផ្សេងៗ ឬប្រាក់បេសកកម្មរបស់មន្ត្រីរាជការ។

**ប្រការ១០:** ការចំណាយថវិកាសម្រាប់ការងារអន្តរាគមន៍ជួសជុលបន្ទាន់ផ្លូវជនបទ ស្ពាន និងលូ ត្រូវស្ថិតក្រោមកម្មវត្ថុនៃការត្រួតពិនិត្យ អធិការកិច្ច និងសវនកម្មតាមក្រោយ។ ដើម្បីសម្រួលដល់ការងារនេះ របាយការណ៍ចំណាយត្រូវច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ហើយត្រូវមានមូលហេតុនៃការខូចខាតផងដែរ។

**ប្រការ១១:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ និង ប្រកាសលេខ ២៧៨ សហវ.ប្រក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១២:** នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធ និងអគ្គាធិការនៃអគ្គាធិការដ្ឋាន ព្រមទាំងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងអភិវឌ្ឍន៍ជនបទ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត
- ដូចប្រការ ១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ